ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ ១៦៦ សជណ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តរតនគិរី**

**កម្មវត្ថុ ៖** របាយការណ៍ស្តីពីលទ្ធផល នៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥។

**យោង ៖** -របាយការណ៍ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា៖ ចំពោះរបាយការណ៍របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ទាក់ទងនឹងការវាយតម្លៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ០៤ ក្រុមហ៊ុន ស្ថិតក្នុងខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី រាជរដ្ឋាភិបាលសម្រេចដូចខាងក្រោម៖

**I- ខេត្តបន្ទាយមានជ័យ**

**-ក្រុមហ៊ុន ឈុន លីម គ្រុប** (CHHUN LIM GROUP CO., LTD)

១-អនុញ្ញាតឱ្យក្រុមហ៊ុន ឈុន លីម គ្រុប (CHHUN LIM GROUP CO., LTD) ក្នុងតំបន់ការពារទេសភាពបន្ទាយឆ្មារ ភូមិសាស្ត្រខេត្តបន្ទាយមានជ័យ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

## II- ខេត្តបាត់ដំបង

**-ក្រុមហ៊ុន សួន មាន សម្បត្តិ ខូ.អិលធីឌី** (SOUN MEAN SAMBATH Co., LTD)

១-អនុញ្ញាតឱ្យក្រុមហ៊ុន **សួន មាន សម្បត្តិ ខូ.អិលធីឌី** (SOUN MEAN SAMBATH Co., LTD) ក្នុងតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំ ភូមិសាស្ត្រស្រុកសំពៅលូន និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

## III- ខេត្តមណ្ឌលគិរី

**-ក្រុមហ៊ុន** MEGA FIRST CORPORATION BERHAD (MFCB)

១-អនុញ្ញាតឱ្យក្រុមហ៊ុន **MEGA FIRST CORPORATION BERHAD (MFCB)** ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំណាមលៀរ ភូមិសាស្ត្រខេត្តមណ្ឌលគិរី បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យាឡើងវិញដោយទុករយៈពេល **០១ (មួយ) ឆ្នាំ** និងកែសម្រួលរយៈពេលវិនិយោគពី **៩០ (កៅសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តមណ្ឌលគិរី ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឱ្យបានហ្មត់ចត់បំផុត ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តតាមការកំណត់ខាងលើ ក្រសួងបរិស្ថានត្រូវរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីសម្រេចដកហូត។

៣-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

## IV- ខេត្តរតនគិរី

**-ក្រុមហ៊ុន វ័ន្ន សុខន អ៊ិនខមភើរសិន ៖**

១-អនុញ្ញាតឱ្យក្រុមហ៊ុន **វ័ន្ន សុខន អ៊ិនខមភើរសិន** ក្នុងតំបន់ដែនជម្រកសត្វព្រៃលំផាត់ ភូមិសាស្ត្រខេត្តរតនគិរី បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យាឡើងវិញ ដោយទុករយៈពេល **០១ (មួយ) ឆ្នាំ** និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តរតនគិរី ត្រូវត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឱ្យបានហ្មត់ចត់បំផុត ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តតាមការកំណត់ខាងលើ ក្រសួងបរិស្ថានត្រូវរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីសម្រេចដកហូត។

៣-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ជ្រាប និងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុក[illegible]ស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**[illegible] សំរេច**

**ចម្លងជូន៖**
-ក្រសួងមហាផ្ទៃ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងធនធានទឹក និងឧតុនិយម
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងរ៉ែ និងថាមពល
-អង្គភាពប្រឆាំងអំពើពុករលួយ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-សមាជិកគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
-ឯកសារ-កាលប្បវត្តិ